# ព័ត៌មានថ្មីស្តីអំពីការចែកអាហារ ការធ្វើតេស្តជំងឺកូវីឌ ការមើលថែទាំកុមារ និងព័ត៌មានផ្សេងៗទៀត

## ការចែកអាហារ

ក្រសួងអប់រំឡុងប៊ីច ដែលបានចែកអាហារពេលព្រឹកនិងថ្ងៃត្រង់នៅតាមទីតាំងចំនួន៣៤កន្លែងក្នុងពេលដែល សាលារៀនបិទទ្វារ នឹងបន្ថែមអាហារសម្រាប់ពេលល្ងាចទៀត នៅតាមទីតាំងចំនួន២៧កន្លែង ចាប់ពីថ្ងៃច័ន្ទ ទី៤ ខែឧសភាទៅ។ អាហារទាំងបីពេលនេះ(ព្រឹក ថ្ងៃត្រង់ និងល្ងាច)នឹងមានចែកឱ្យនៅក្នុងពេលម៉ោងចែកអាហារធម្មតា គឺពីម៉ោង១១:៣០ថ្ងៃទៅដល់ ១២:៣០ថ្ងៃ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។

សាលារៀនដែលមានចែកអាហារសម្រាប់ទាំងបីពេលនេះគឺសាលា Addams, Avalon, Birney, Bixby, Burbank, Chavez, Dooley, Garfield, Gompers, Grant, Harte, Herrera, King, Lafayette, Lincoln, Lindbergh, McKinley, Oropeza, Riley, Roosevelt, Signal Hill, Smith, Twain, Washington, Webster, Whitter និង Willard ។

សាលារៀនចំនួន៧ទៀតនឹងបន្តចែកអាហារពេលព្រឹកនិងថ្ងៃត្រង់ ប៉ុន្តែពុំមានអាហារសម្រាប់ពេលល្ងាចទេ នៅក្នុងពេលម៉ោងចែកអាហារ ធម្មតាពីម៉ោង១១:៣០ថ្ងៃដល់១២:៣០ថ្ងៃ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។ សាលាទាំងនោះគឺ Emerson, Gant, Henry, Hughes, MacArthur, Marshall និង Rogers ។

មាតាបិតាអាចបន្តទៅយកអាហារដោយពុំមាននាំកូនទៅជាមួយនៅតាមសាលារៀនចំនួន៣៤កន្លែងដោយបង្ហាញក្រដាសស្នាមដែលមានឈ្មោះកូនគាត់ដើម្បីផ្ទៀងឱ្យត្រូវគ្នាជាមួយលេខសម្គាល់ខ្លួនរបស់សិស្សសម្រាប់ទទួលអាហារ។ ចុចកន្លែងនេះដើម្បីរកមើលផែនទីសាលារៀន View a map of LBUSD school locations here ឬចូលទៅគេហទំព័រក្រសួងអប់រំ នៅ lbschools.net រួចចុចលើពាក្យ ABOUT > Map ។ លោកអ្នកក៏អាចឆែករកមើលក្នុងបណ្តាញ Instagram របស់សេវាកម្មចែកចាយអាហារនៅ @lbusdnutrition ដើម្បីព័ត៌មានបន្ថែមនិងបច្ចុប្បន្នភាពប្រចាំថ្ងៃ។

## ការធ្វើតេស្តជំងឺកូវីឌ១៩

បន្ទាប់ពីសេចក្តីប្រកាសថ្មីៗរបស់ចៅហ្វាយខេត្ត Gavin Newsom ក្នុងការបង្កើតកន្លែងធ្វើតេស្តចំនួន៨០កន្លែងថែមទៀតនៅក្នុងសហគមន៍ទូទាំងរដ្ឋកាលីហ្វ័រនីញ៉ា ជាពិសេសនៅតាមសហគមន៍ដែលមិនធ្លាប់បានទទួលការយកចិត្តទុកដាក់ច្រើន ក្រុងឡុងប៊ីច នឹងចាប់ផ្តើមបើកកន្លែងធ្វើតេស្តថ្មីមួយទៀតនៅថ្ងៃស្អែកនេះ នៅសាលាវិទ្យាល័យ Jordan Plus High School (171 W. Bort St.) ។ ការធ្វើតេស្តនឹងមានប្រព្រឹត្តធ្វើទៅនៅវិទ្យាល័យ Jordan Plus High School ពីម៉ោង 7 ព្រឹកទៅដល់ 7 ល្ងាច ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ នៅក្នុងចំណតរថយន្តសាលារៀន។ ការធ្វើតេស្តនៅថ្ងៃទី៣០ មេសា និងថ្ងៃទី១ឧសភាគឺសម្រាប់តែអ្នកធ្វើការជួរមុខ ដែលមានរួមទាំងអ្នកសង្គ្រោះបន្ទាន់ បុគ្គលិកសំខាន់របស់រដ្ឋ ពេទ្យឬអ្នកធ្វើការថែសុខភាពនិងព្យាបាលជំងឺ ហើយនិងអ្នកធ្វើការនៅហាងលក់ស្បៀងអាហារ។ (សូមទូរស័ព្ទទៅលេខ 888-634-1123 ដើម្បីដាក់ពេលណាត់ជួប)។ ចាប់ពីថ្ងៃច័ន្ទ ទី៤ខែឧសភា សមាជិកទូទៅនៅក្នុងសហគមន៍ដែលមានរោគសញ្ញា ថែមពីអ្នកធ្វើការសំខាន់ៗ អាចទៅធ្វើតេស្តនៅសាលា Jordan Plus ។ ប្រព័ន្ធដាក់ពេលណាត់ជួប appointment scheduling platform នឹងចាប់ដំណើរការតាមអនឡាញនៅថ្ងៃទី២ឧសភា សម្រាប់ការដាក់ពេលណាត់ជួបសម្រាប់សប្តាហ៍បន្ទាប់។

## ការមើលថែកុមារ

អង្គការមិនយកប្រាក់ចំណេញ Pacific Gateway Workforce Partnership បានផ្តើមកម្មវិធី **WorkLB**, តាមរយៈប្រព័ន្ធអេឡិកត្រូនិកដោយមិនគិតថ្លៃ ដែលជួយបន្តភ្ជាប់ទៅនឹងអ្នកមើលថែកុមារដល់សាធារណៈជនណាដែលត្រូវការការមើលថែកុមារដែលមានគុណភាពដោយប្រចុចញ៉ុច។ ដើម្បីព័ត៌មានបន្ថែមសូមទូរស័ព្ទ (562) 570-4249.

## ព័ត៌មាននិងធនធានផ្សេងៗ

រកមើលធនធាននិងព័ត៌មានបន្ថែមអំពីការបិទទ្វារសាលានៅគេហទំព័ររបស់ក្រសួងអប់រំនៅ lbschools.net ។